## សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងមេរោគ HPV Gardasil® (Human Papillomavirus)

## អ្វីដែលអ្នកត្រូវដឹង

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សន្លឹកព័ត៌មានស្ដីពីថ្នាំវ៉ាក់សាំងជាច្រើនមានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ សូមចូលទៅ www.immunize.org/vis

## 1 តើមេរោគ HPVគឺជាមេរោគអ្វី?

មេរោគ **human papillomavirus (HPV)** គឺជាមេរោគចម្លងតាមផ្លូវភេទទូទៅបំផុតនៅសហរដ្ឋអាមេរិក។ បុរស និងស្ត្រីរួមភេទចំនួនជាងពាក់កណ្ដាលឆ្លងមេរោគ HPV នៅពេលណាមួយក្នុងជីវិតរបស់ពួកគេ។

បច្ចុប្បន្ន ពលរដ្ឋអាមេរិកប្រហែល 20 លាននាក់ឆ្លងមេរោគនេះ ហើយមនុស្សប្រហែល 6 លាននាក់បន្ថែមទៀតបានឆ្លងមេរោគនេះជារៀងរាល់ឆ្នាំ។ ជាធម្មតា មេរោគ HPV ឆ្លងតាមការប៉ះពាល់ផ្លូវភេទ។

មេរោគ HPV ភាគច្រើនពុំបង្កជារោគសញ្ញាទេ ហើយបាត់ទៅវិញដោយខ្លួនឯង។ ប៉ុន្តែ HPV អាចបង្ក**ជំងឺមហារីកកស្បូន**ចំពោះស្ត្រី។ ជំងឺមហារីកកស្បូនគឺជាជំងឺមហារីកនាំមុខទី 2 ដែលបណ្ដាលឲ្យស្ត្រីស្លាប់បាត់បង់ជីវិតនៅទូទាំងពិភពលោក។ នៅសហរដ្ឋអាមេរិក ស្ត្រីប្រហែល 12,000 នាក់កើតជំងឺមហារីកកស្បូនរៀងរាល់ឆ្នាំ ហើយមនុស្សប្រហែល 4,000 នាក់ត្រូវបានរំពឹងថានឹងស្លាប់បាត់ជីវិតដោយសារជំងឺនេះ។

មេរោគ HPV ក៏ពាក់ព័ន្ធនឹងជំងឺមហារីកជាច្រើនផងដែរដែលមិនសូវទូទៅ ដូចជាជំងឺមហារីករន្ធ និងប្រហោងយោនីចំពោះស្ត្រី និងជំងឺមហារីករន្ធគូទ និងមាត់បំពង់ក (បំពង់ក គុលអណ្ដាត និងដុំសាច់បំពង់ក) ចំពោះទាំងបុរស និងស្ត្រី។ មេរោគ HPV ក៏អាចបង្កជំងឺឫសលើប្រដាប់ភេទ និងឫសក្នុងបំពង់ក។

ពុំមានថ្នាំព្យាបាលមេរោគ HPV ទេ ប៉ុន្តែបញ្ហាមួយចំនួន ដែលមេរោគនេះបង្ក អាចព្យាបាលបាន។

## 2 ថ្នាំវ៉ាក់សាំងមេរោគ HPV៖ ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

ថ្នាំវ៉ាក់សាំងមេរោគ HPV ដែលលោកអ្នកកំពុងទទួលនេះ គឺជាប្រភេទមួយនៃថ្នាំវ៉ាក់សាំងពីរប្រភេទ ដែលអាចចាក់ដើម្បីបង្ការមេរោគ HPV បាន។ ថ្នាំវ៉ាក់សាំងនេះអាចចាក់បានទាំងបុរស និងស្ត្រី។

ថ្នាំវ៉ាក់សាំងនេះអាចបង្ការករណីភាគច្រើននៃជំងឺមហារីកកស្បូនចំពោះស្រ្តី ប្រសិនបើបានចាក់ថ្នាំវ៉ាក់សាំងមុនពេលឆ្លងមេរោគនេះ។ លើសពីនេះ ថ្នាំវ៉ាក់សាំងនេះអាចបង្ការជំងឺមហារីករន្ធ និងប្រហោងយោនីបានចំពោះស្ត្រី និងឫសលើប្រដាប់ភេទ និងជំងឺមហារីករន្ធគូទចំពោះទាំងបុរស និងស្ត្រី។

ការការពារដោយថ្នាំវ៉ាក់សាំងមេរោគ HPV នេះត្រូវបានរំពឹងថា មានរយៈពេលវែង។ ប៉ុន្តែការចាក់ថ្នាំវ៉ាក់សាំងមិនអាចជាវិធីជំនួសការពិនិត្យរកជំងឺមហារីកកស្បូនឡើយ។ ស្ត្រីគួរតែធ្វើតេស្តរកជំងឺមហារីកកស្បូនជាប្រចាំ។

## 3 តើអ្នកណាគួរទទួលថ្នាំវ៉ាក់សាំងមេរោគ HPV នេះ ហើយនៅពេលណា?

***ថ្នាំវ៉ាក់សាំងមេរោគ HPV គឺចាក់ 3 ដូស។***

| | |
|---|---|
| ដូសទី 1 | ឥឡូវនេះ |
| ដូសទី 2 | 1 ទៅ 2 ខែ បន្ទាប់ពីដូសទី 1 |
| ដូសទី 3 | 6 ខែបន្ទាប់ពីដូសទី 1 |

ដូសបន្ថែម (ដូសរំឭក) ពុំបានណែនាំឲ្យចាក់ទេ។

**ការចាក់ថ្នាំវ៉ាក់សាំងជាទម្លាប់**

- ថ្នាំវ៉ាក់សាំងមេរោគ HPV នេះត្រូវសម្រាប់ក្មេងស្រី និងក្មេងប្រុសអាយុ **11 ឬ 12 ឆ្នាំ**។ ថ្នាំវ៉ាក់សាំងនេះ*អាច* ចាក់ចាប់ផ្ដើមនៅអាយុ 9 ឆ្នាំ។

  **ហេតុអ្វីថ្នាំវ៉ាក់សាំងមេរោគ HPV ត្រូវបានណែនាំឲ្យចាក់នៅអាយុ 11 ឬ 12 ឆ្នាំ?** មេរោគ HPV គឺជាមេរោគងាយឆ្លង សូម្បីតែជាមួយដៃគូរួមភេទតែម្នាក់ក៏ដោយ។ នោះជាមូលហេតុដែលជាការសំខាន់ត្រូវចាក់ថ្នាំវ៉ាក់សាំងមេរោគ HPV មុនពេលមានការប៉ះពាលផ្លូវភេទ។ម្យ៉ាងទៀត ការឆ្លើយតបនឹងថ្នាំវ៉ាក់សាំងគឺល្អប្រសើរនៅវ័យនេះជាងវ័យចាស់ជាងនេះ។

**ការចាក់ថ្នាំវ៉ាក់សាំងឲ្យទាន់ពេល**

ថ្នាំវ៉ាក់សាំងត្រូវបានណែនាំសម្រាប់មនុស្សដូចខាងក្រោម ដែលពុំបានទទួលថ្នាំវ៉ាក់សាំងគ្រប់ 3 ដូស។

- ស្ត្រីអាយុ 13 ដល់ 26 ឆ្នាំ
- បុរសអាយុ 13 ដល់ 21 ឆ្នាំ

ថ្នាំវ៉ាក់សាំងនេះ*អាច* ផ្ដល់ឲ្យបុរសអាយុ 22 ឆ្នាំដល់ 26 ឆ្នាំដែលពុំបានទទួលថ្នាំវ៉ាក់សាំងនេះគ្រប់ 3 ដូស។

ថ្នាំវ៉ាក់សាំងនេះត្រូវបាន*ណែនាំ*សម្រាប់បុរសអាយុ 26 ឆ្នាំ ដែលរួមភេទជាមួយនឹងបុរស ឬដែលប្រព័ន្ធស៊ាំចុះខ្សោយ ដោយសារមេរោគអេដស៍ ជំងឺ ឬឱសថដទៃទៀត។

ថ្នាំវ៉ាក់សាំងមេរោគ HPV អាចចាក់ក្នុងពេលជំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

HPV (Gardasil) VIS - Khmer (5/17/13)

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 4 មនុស្សមួយចំនួនមិនគួរចាក់ថ្នាំវ៉ាក់សាំងមេរោគ HPV ទេ ឬគួររង់ចាំ។

- ជនណាដែលធ្លាប់មានប្រតិកម្មអាឡាក់ស៊ីនឹងធាតុផ្សំនៃថ្នាំវ៉ាក់សាំងមេរោគ HPV ឬដូសមុននៃថ្នាំវ៉ាក់សាំងមេរោគ HPV ដែលគំរាមដល់អាយុជីវិត មិនគួរទទួលថ្នាំវ៉ាក់សាំងនេះទេ។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើអ្នកដែលចាក់ថ្នាំវ៉ាក់សាំង មានប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ដែលរួមបញ្ចូលទាំងប្រតិកម្មអាឡាក់ស៊ីទៅនឹងមេដំបែ។
- ថ្នាំវ៉ាក់សាំងមេរោគ HPV ពុំត្រូវបានណែនាំសម្រាប់ស្ត្រីមានផ្ទៃពោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការទទួលថ្នាំវ៉ាក់សាំងមេរោគ HPV ពេលមានផ្ទៃពោះ មិនមែនជាហេតុផលក្នុងការពិចារណាបញ្ចប់ការមានផ្ទៃពោះឡើយ។ ស្ត្រីបំបៅដោះកូនអាចទទួលថ្នាំវ៉ាក់សាំងនេះបាន។
- អ្នកដែលមានជំងឺស្រាល ពេលគ្រោងចាក់ថ្នាំវ៉ាក់សាំងមេរោគ HPV នេះ នៅតែអាចចាក់ថ្នាំវ៉ាក់សាំងបាន។ អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ គួររង់ចាំសិនរហូតទាល់តែពួកគេជាសះស្បើយសិន។

## 5 តើមានហានិភ័យអ្វីខ្លះដោយសារថ្នាំវ៉ាក់សាំងនេះ?

ថ្នាំវ៉ាក់សាំងមេរោគ HPV នេះត្រូវបានប្រើប្រាស់នៅសហរដ្ឋអាមេរិក និងទូទាំងពិភពលោករយៈពេលប្រហែល 6 ឆ្នាំកន្លងមកហើយ ហើយថ្នាំវ៉ាក់សាំងនេះមានសុវត្ថិភាពណាស់។

ទោះជាយ៉ាងណា ថ្នាំវ៉ាក់សាំងអាចបង្កបញ្ហាធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ។ ហានិភ័យដែលថ្នាំវ៉ាក់សាំងនេះបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតនោះ គឺមានកម្រិតតិចតួចបំផុត។

កម្រមានប្រតិកម្មអាឡាក់ស៊ីដែលគំរាមដល់អាយុជីវិតដោយសារថ្នាំវ៉ាក់សាំងណាស់។ ប្រសិនបើមានប្រតិកម្ម វានឹងមានរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះ បន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំង។

បញ្ហា**ស្រាល** និង **ធ្ងន់ល្មម**ជាច្រើន ត្រូវបានគេដឹងថា កើតឡើងជាមួយនឹងថ្នាំវ៉ាក់សាំងមេរោគ HPV នេះ។ បញ្ហាទាំងនេះមិនកើតឡើងរយៈពេលយូរទេ ហើយបាត់ទៅវិញដោយខ្លួនឯង។

- ប្រតិកម្មលើដៃដែលចាក់ថ្នាំ
  - ការឈឺចុកចាប់ (មនុស្សប្រហែល 8 នាក់ក្នុងចំណោម10 នាក់)
  - ឡើងក្រហម ឬហើម (មនុស្សប្រហែលម្នាក់ក្នុងចំណោម 4 នាក់)
- គ្រុនក្តៅ ៖
  - ស្រាល (100° F) (មនុស្សប្រហែលម្នាក់ក្នុងចំណោម10នាក់)
  - ធ្ងន់ល្មម (102° F) (មនុស្សប្រហែលម្នាក់ក្នុងចំណោម 65 នាក់)
- បញ្ហាដទៃទៀត ៖
  - ឈឺក្បាល( មនុស្សប្រហែលម្នាក់ក្នុងចំណោម 3 នាក់)
- ការសន្លប់ ៖ ការសន្លប់រយៈពេលខ្លី និងរោគសញ្ញាពាក់ព័ន្ធ (ដូចជា កន្ត្រាក់) អាចកើតឡើង បន្ទាប់ពីដំណើរការវេជ្ជសាស្ត្រ ដែលរួមបញ្ចូលទាំងការចាក់ថ្នាំវ៉ាក់សាំងផងដែរ។ ការអង្គុយ ឬដេកប្រហែល 15 នាទីបន្ទាប់ពីចាក់ថ្នាំវ៉ាក់សាំងអាចជួយបង្ការការសន្លប់ និងរបួសដោយសារដួល។ សូមប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក ប្រសិនបើលោកអ្នកមានអារម្មណ៍វិលមុខ ឬការមើលឃើញមានការប្រែប្រួល ឬហឹងត្រចៀក។

  ដូចថ្នាំវ៉ាក់សាំងទាំងអស់ដែរ គេនឹងបន្តតាមដានរកបញ្ហាខុសធម្មតា ឬធ្ងន់ធ្ងរនានា ដោយសារថ្នាំវ៉ាក់សាំងមេរោគ HPV។

## 6 ចុះបើមានប្រតិកម្មធ្ងន់ធ្ងរ?

**តើខ្ញុំគួរប្រយ័ត្នចំពោះអ្វីខ្លះ?**

- សូមប្រយ័ត្នចំពោះអ្វីដែលធ្វើឲ្យលោកអ្នកព្រួយបារម្ភ ដូចជាសញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ គ្រុនក្តៅខ្លាំង ឬការប្តូរឥរិយាបថ។

  សញ្ញាបង្ហាញពីប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ អាចរួមបញ្ចូលកន្ទួល ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម ចង្វាក់បេះដូងញាប់ វិលមុខ និងកម្លាំងចុះខ្សោយ។ បញ្ហាទាំងនេះនឹងចាប់ផ្តើមកើតឡើងរយៈពេលប៉ុន្មាននាទីទៅប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីការចាក់ថ្នាំវ៉ាក់សាំង។

**តើខ្ញុំគួរធ្វើអ្វីខ្លះ?**

- ប្រសិនបើលោកអ្នកគិតថា វាគឺជាប្រតិកម្មអាឡាក់ស៊ីធ្ងន់ធ្ងរ ឬស្ថានការណ៍សង្គ្រោះបន្ទាន់ដទៃទៀតដែលមិនអាចរង់ចាំបាន សូមទូរស័ព្ទទៅ 9-1-1 ឬយកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលជិតបំផុត។ បើមិនអញ្ចឹងទេ សូមទូរស័ព្ទទៅវេជ្ជបណ្ឌិតរបស់លោកអ្នក។
- បន្ទាប់មក ប្រតិកម្មគួររាយការណ៍ទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (Vaccine Adverse Event Reporting System (VAERS))។ វេជ្ជបណ្ឌិតរបស់លោកអ្នកអាចដាក់បញ្ជូនរបាយការណ៍នេះ ឬលោកអ្នកអាចរាយការណ៍ដោយផ្ទាល់តាមរយៈវេបសាយ VAERS នៅ **www.vaers.hhs.gov** ឬតាមរយៈហៅទូរស័ព្ទមក **1-800-822-7967**។

*VAERS គឺសម្រាប់តែការរាយការណ៍ប្រតិកម្មផ្សេងៗប៉ុណ្ណោះ។ ប្រព័ន្ធនេះពុំផ្តល់ដំបូន្មានវេជ្ជសាស្ត្រទេ។*

## 7 កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program)

កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។

បុគ្គលដែលជឿជាក់ថា ខ្លួនអាចធ្លាប់រងរបួសដោយសារថ្នាំវ៉ាក់សាំងមួយ អាច ធ្វើការសិក្សាអំពីកម្មវិធី និងអំពីការដាក់ពាក្យទាមទារសំណង ដោយទូរស័ព្ទមក **1-800-338-2382** ឬចូលទៅវេបសាយ VICP នៅ **www.hrsa.gov/vaccinecompensation**។

## 8 តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរវេជ្ជបណ្ឌិតរបស់លោកអ្នក។ 1-888-767-4687
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- ទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់និងបង្ការជំងឺឆ្លង (CDC)៖
  - ទូរស័ព្ទមកលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលទៅវេបសាយ CDC នៅ **www.cdc.gov/vaccines**

DCH-1339CA
AUTH: P. H. S., Act 42, Sect. 2126.
Translation provided by the Immunization Action Coalition

Vaccine Information Statement (Interim)
# HPV Vaccine (Gardasil)

5/17/2013 Khmer
42 U.S.C. § 300aa-26
Office Use Only

ដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ការព្យាបាលសុខភាពស្នើសុំនូវពត៌មានអំពីការចាក់ថ្នាំបង្ការរោគពេញលក្ខណត្រឹមត្រូវ, ការពិនិត្យមើលនៃការចាក់ថ្នាំបង្ការរោគ ហើយនិងការតម្រូវដាក់ពេលវេលា សំរាប់ចាក់ថ្នាំបង្ការរោគនៅអនាគត, ពត៌មានអំពីការចាក់បង្ការរោគនឹងផ្ញើទៅមន្ទីរ Michigan Care Improvement Registry ។ បុគ្គលទាំងឡាយមានសិទ្ធិស្នើសុំអោយអ្នកផ្តល់ការព្យាបាលសុខ ភាពមិនអោយបញ្ជូនពត៌មានអំពីការចាក់ថ្នាំបង្ការរោគនេះទៅឲ្យកន្លែងទុកសំណុំរឿងបាន។